# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៧៥...សសរ...

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩ នៅទីក្រុងសៀមរាប ឆ្នាំ២០១៦

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-** ត្រូវបានបង្កើតគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩ ដែលនឹងប្រារព្ធធ្វើនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅខេត្តសៀមរាប ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២-ឯកឧត្តម **ម៉ៅ ថូរ៉ា** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | អនុប្រធាននិងជាឧត្តមមន្ត្រី |
| ៣-ឯកឧត្តម **ខឹវ ម៉ាស្រ៊ុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៥-លោកជំទាវ **តឹករ៉េត កំរេខ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិកា |
| ៦-ឯកឧត្តមនាយឧត្តមសេនីយ៍ **នាង ផាត** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ៧-ឯកឧត្តម **ម៉ៅ ហាវណ្ណាល់** | រដ្ឋលេខាធិការរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ៨-ឯកឧត្តម **ហេង តៃគ្រី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៩-ឯកឧត្តម **ថៃ នរៈសត្យា** | រដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១០-ឯកឧត្តម **ម៉េង សុធី** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១-ឯកឧត្តម **សុខ សុភ័ក្ត្រ** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២-ឯកឧត្តម **ពេជ ឬទ្ធី** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣-ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |
| ១៤-ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៥-ឯកឧត្តម **ឃឹម ប៊ុនសុង** | អភិបាលនៃគណៈអភិបាលខេត្តសៀមរាប | សមាជិក |
| ១៦-ឯកឧត្តម **កឹម គុណាវឌ្ឍន៍** | អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ១៧-ឯកឧត្តម **ស៊ាង ថៃ** | អគ្គនាយកជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៨-ឯកឧត្តម **អ៊ុក ធី** | អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៩-ឯកឧត្តម **ស៊ឹម សុខខេង** | អគ្គនាយកពាណិជ្ជកម្មអន្តរជាតិក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២០-លោក **ណុប សោភ័ណតារា** | ប្រធាននាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិកក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ២.**-គណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំកម្មវិធីប្រជុំ និងចាត់ចែងការងារពិធីការឲ្យបានសមស្រប និងថ្លៃថ្នូរ
- សម្របសម្រួល និងរៀបចំការពារសន្តិសុខជូនគណៈប្រតិភូ ដែលអញ្ជើញចូលរួមកិច្ចប្រជុំឲ្យមានសុវត្ថិភាពល្អ
- សិក្សា ស្រាវជ្រាវ និងចងក្រងឯកសារសំខាន់ៗសម្រាប់កិច្ចប្រជុំ
- រៀបចំមន្ទីរពេទ្យ គ្រូពេទ្យប្រចាំការ និងសង្គ្រោះបន្ទាន់ នៅតាមគោលដៅចាំបាច់
- ចាត់ចែងការសម្តែងសិល្បៈប្រពៃណីជូនគណៈប្រតិភូក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ
- សម្របសម្រួលជាមួយប្រព័ន្ធឃោសនាជាតិ និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយព័ត៌មានជុំវិញការរៀបចំកិច្ចប្រជុំ
- សម្របសម្រួល និងចាត់ចែងកិច្ចការទូទៅពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំខាងលើ ឲ្យទទួលបានលទ្ធផលល្អប្រសើរ
- រៀបចំគម្រោងចំណាយសម្រាប់ការរៀបចំកិច្ចប្រជុំខាងលើ រួចលើកសំណើសុំថវិកាពីរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការចាំបាច់។

**ប្រការ៣.**- ប្រធានគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាម លើកទី៩ មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញផ្សេងទៀត តាមការចាំបាច់ ដើម្បីធានាឲ្យការរៀបចំកិច្ចប្រជុំទទួលបានលទ្ធផលល្អប្រសើរ។

**ប្រការ៤.-** សមាជិកគណៈកម្មការរៀបចំកិច្ចប្រជុំកំពូលកម្ពុជា-ឡាវ-វៀតណាមលើកទី៩ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៥.-** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អភិបាលនៃគណៈអភិបាលខេត្តសៀមរាប រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ